ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃ អង្គារ ០៥ កើត ខែ ជេស្ឋ ឆ្នាំ ជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០២០

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីជំនួបរវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

នាព្រឹកថ្ងៃ អង្គារ ទី ២៦ ខែ ឧសភា ឆ្នាំ ២០២០, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបសម្តែងការគួរសមជាមួយលោកបណ្ឌិត **ប៊ិច សុខែម** នាយកប្រតិបត្តិនៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (Cambodian Development Resource Institute - CDRI) ដែលទើបត្រូវបានជ្រើសតាំង និងចូលកាន់តំណែងកន្លងទៅនេះ ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី បានចូលរួមអបអរសាទរជាមួយនឹងលោកបណ្ឌិត **ប៊ិច សុខែម** ក្នុងការទទួលតួនាទីថ្មីជានាយកប្រតិបត្តិរបស់វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ។ ទន្ទឹមនេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏ថ្លែងអំណរគុណដល់វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ក្នុងការបន្តរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកម្ពុជា តាមរយៈការសិក្សាស្រាវជ្រាវនានាពាក់ព័ន្ធនឹងគោលនយោបាយតាមវិស័យសំខាន់ៗនារយៈពេលជិត ០៣ ទសវត្សរ៍មកនេះ ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានធ្វើការចង្អុលបង្ហាញបន្ថែមទាក់ទិននឹងកិច្ចសហការរួមគ្នារវាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា លើកិច្ចការស្រាវជ្រាវគោលនយោបាយជាយុទ្ធសាស្ត្រ ដើម្បីបម្រើជាធាតុចូលដ៏សំខាន់ក្នុងការកសាងគោលនយោបាយអភិវឌ្ឍន៍ជាតិ ។ បន្ថែមពីនេះទៀត, ដើម្បីធ្វើឱ្យការសិក្សាស្រាវជ្រាវរបស់វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាមានភាពប្រទាក់ក្រឡាគ្នាដ៏ស្អិតរមួតជាមួយតម្រូវការគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានផ្តល់ជាអនុសាសន៍បន្ថែមដល់វិទ្យាស្ថានទៅលើប្រធានបទ ដែលគួរធ្វើការសិក្សាឱ្យស៊ីជម្រៅបន្ថែមទៀតរួមមាន÷ ការកសាងគោលនយោបាយសេដ្ឋកិច្ចឌីជីថល, ការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ចសកលលោកក្រោយជំងឺកូវីដ-១៩, ការធ្វើឱ្យមានតុល្យភាពឡើងវិញរវាងគោលនយោបាយកំណើនពឹងលើការនាំចេញ និងសេដ្ឋកិច្ចពឹងផ្អែកលើខ្លួនឯង, ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច ។ល។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏ធ្វើការគូសបញ្ជាក់បន្ថែមទៀតផងដែរថា រាជរដ្ឋាភិបាលបាននិងកំពុងកសាងឯកសារទស្សនវិស័យកម្ពុជា ក្នុងការប្រែក្លាយខ្លួនជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ ឆ្នាំ ២០៣០ និងប្រទេសមាន

ប្រាក់ចំណូលខ្ពស់ឆ្នាំ ២០៥០ ដែលទស្សនវិស័យនេះជាគោលដៅរួមរបស់ប្រជាជាតិកម្ពុជាទាំងមូល ហើយរាជរដ្ឋាភិបាលក៏មានតម្រូវការជាធាតុចូលនានាបន្ថែមដែរពីដៃគូពាក់ព័ន្ធ ។ ក្នុងន័យនេះ, វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា គួរពិចារណាដាក់ប្រធានបទពាក់ព័ន្ធនឹងការកសាងគោលនយោបាយគាំទ្រការអភិវឌ្ឍជំនាញ និងស្រូបទាញមូលធន និងបច្ចេកវិទ្យា ជារបៀបវារៈក្នុងការសិក្សាស្រាវជ្រាវរបស់ខ្លួនផងដែរ ។

លោកបណ្ឌិត **ប៊ិច សុខេម** ក៏បានគោរពថ្លែងអំណរគុណដល់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ក្នុងការចែករំលែកអនុសាសន៍នានាសម្រាប់ជាទិសដៅសិក្សាស្រាវជ្រាវនាពេលខាងមុខ ហើយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នឹងបន្តប្តេជ្ញារួមចំណែកយ៉ាងសកម្មក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទថ្មីៗ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកម្ពុជា ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី ក៏បានជូនពរលោកបណ្ឌិត **ប៊ិច សុខេម** និងសហការី ទទួលបានជោគជ័យលើការសិក្សាស្រាវជ្រាវរបស់ខ្លួនបន្តទៀតផងដែរ ។